**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
លេខ ០០៣/សសាន/២០២០

# សេចក្តីណែនាំ
## ស្តីពី
## វិធានការពង្រឹងអនុវត្តន៍ លក្ខន្តិកៈទូទៅចំពោះយោធិននៃ.ខ.ភ.ម បទវិន័យទូទៅសម្រាប់.ខ.ភ.ម និងលំហាត់របៀបនៃកងយោធពលខេមរភូមិន្ទ

កងយោធពលខេមរភូមិន្ទ ជាកងទ័ពរបស់ព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចបម្រើប្រទេសជាតិមាតុភូមិ។ បេសកកម្មរបស់កងយោធពលខេមរភូមិន្ទ គឺការពារ កសាង ជាតិមាតុភូមិ ដើម្បីផលប្រយោជន៍ ដ៏ខ្ពង់ខ្ពស់របស់ប្រទេសជាតិ ក្នុងកាលៈទេសៈចាំបាច់ កងយោធពលខេមរភូមិន្ទនឹងអាចចូលរួមក្នុងការការពារសន្តិសុខសាធារណៈ និងជួយប្រជាពលរដ្ឋដែលជួបការលំបាក ឬមានគ្រោះមហន្តរាយ។ ដើម្បីអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈចំពោះយោធិននៃ.ខ.ភ.ម និងអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់.ខ.ភ.មខាងលើឱ្យមានប្រសិទ្ធភាពយោធិនកងយោធពលខេមរភូមិន្ទ ត្រូវគោរពវិន័យឱ្យបានម៉ឺងម៉ាត់ ភក្តីភាព សាមគ្គីភាព និងក្លាហានហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង នៅគ្រប់កាលៈទេសៈ ដើម្បីបុព្វហេតុជាតិមាតុភូមិ។

ដើម្បីឱ្យយោធិននៃកងយោធពលខេមរភូមិន្ទ គោរពវិន័យបានយ៉ាងម៉ឺងម៉ាត់ ភក្តីភាព ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង គ្រប់កាលៈទេសៈ ចំពោះជាតិមាតុភូមិ និងការឯកភាពគ្នា ដោយសេចក្តីថ្លៃថ្នូរ យោធិនគ្រប់រូប ត្រូវគោរពឱ្យបានម៉ឺងម៉ាត់ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃ.ខ.ភ.ម អនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់.ខ.ភ.ម និងលំហាត់របៀបយោធានៃកងយោធពលខេមរភូមិន្ទ ដើម្បីឱ្យយោធិនគ្រប់រូបគោរពវិន័យកាន់តែម៉ឺងម៉ាត់ល្អប្រសើរថែមទៀត ក្រសួងការពារជាតិ សូមធ្វើការណែនាំក្នុងការអនុវត្តចំណុចសំខាន់ៗដូចខាងក្រោម៖

១.យោធិនគ្រប់រូបដែលចង់បកស្រាយជាសាធារណៈ ជាអាទិ៍ការសរសេរ ការធ្វើសន្និសីទឬសេចក្តីថ្លែងការណ៍នូវបញ្ហានយោបាយ ការសម្ងាត់យោធា ឬការចោទប្រកាន់ជនបរទេស ឬអង្គការអន្តរជាតិណាមួយ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ និងភាពជាយោធិន ការប្រើសិទ្ធិកូដកម្ម ឬបាតុកម្ម ត្រូវបានហាមឃាត់(ដូចមានចែងក្នុងជំពូកទី២ មាត្រា១០និង១៣ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ)

២.ការដាក់ទណ្ឌកម្ម ចំពោះយោធិនណាដែលមានកំហុស យោធិនត្រូវទទួលទណ្ឌកម្មយោធា ដោយមិនគិតពីការផ្តន្ទាទោសតាមផ្លូវតុលាការ៖

-ទណ្ឌកម្មខាងផ្នែកវិន័យដែលកំណត់ដោយបទវិន័យទូទៅក្នុងកងយោធពលខេមរភូមិន្ទ

-ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅចំពោះកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងជំពូកទី៧

មាត្រា៤៨,៤៩,៥០និង៥១។

ការវិនិច្ឆ័យ ឬការវាយតម្លៃដាក់ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅ ត្រូវសុំយោបល់ពីក្រុមប្រឹក្សាវិន័យជាមុនសិន។ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ដោយប្រកាសក្រសួងការពារជាតិ។ ក្រោយពីបានទទួលយោបល់ពីក្រុមប្រឹក្សាវិន័យ រដ្ឋមន្ត្រីក្រសួងការពារជាតិ ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងរឿងនេះអាចសម្រេចដាក់ទណ្ឌកម្មតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃ.ខ.ភ.ម និងអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់.ខ.ភ.ម ហើយការសម្រេចខាងផ្នែកវិន័យនិងទណ្ឌកម្ម អាចសម្រេចដាក់ទាំងពីរបាន (ដូចមានចែងក្នុងជំពូកទី៧ មាត្រា៤៥,៤៦,និង៤៧ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ)

៣.យោធិនគ្រប់រូបមានសិទ្ធិ ក្នុងការតវ៉ាចំពោះអ្នកដែលដាក់ទណ្ឌកម្មខ្លួន ឬប្រព្រឹត្តអំពើអយុត្តិ-ធម៌អ្វីមួយមកលើខ្លួន តែបណ្តឹងតវ៉ានេះត្រូវធ្វើតាមរយៈនាយផ្ទាល់ ហើយបញ្ជូនតាមឋានានុក្រម ក្នុងរយៈពេល៣ខែ ចាប់ពីថ្ងៃដែលបានចុះក្នុងសៀវភៅតវ៉ានៃកងឯកភាពខ្លួនរួចមក បើមិនមានចម្លើយឬការដោះស្រាយណាមួយពីអ្នកដឹកនាំ ឬថ្នាក់លើរបស់ខ្លួន សាមីខ្លួនអាចធ្វើលិខិតតវ៉ាទៅស្ថាប័នអធិការកិច្ច ដោយភ្ជាប់នូវសំណុំរឿងរបស់ខ្លួនមកជាមួយផង។ក្រោយពេលដែលបានទទួលសំណុំរឿងនេះហើយស្ថាប័នអធិការកិច្ច ត្រូវធ្វើការស្រាវជ្រាវ និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិសម្រេច សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិត្រូវផ្ញើទៅសាមីជនអ្នកតវ៉ា តាមរយៈស្ថាប័នអធិការកិច្ច ហើយត្រូវចុះក្នុងបញ្ជីតវ៉ាកងឯកភាពខ្លួនផង។ ក្នុងករណីដែលយោធិនតវ៉ាដោយប្រឌិដ្ឋ ហេតុផលមិនសមស្របត្រូវទទួលទណ្ឌកម្មធ្ងន់ថែមទៀត និងការតវ៉ាដោយបង្ហោះជាសាធារណៈ តាមប្រព័ន្ធអ៊ិនធ័រណែតធ្វើឱ្យប៉ះពាល់ដល់កិត្តិយសកងទ័ព ឬថ្នាក់ដឹកនាំត្រូវបានហាមឃាត់។ចំពោះសិទ្ធិតវ៉ានេះ(មានចែងក្នុងជំពូកទី៤ មាត្រា១៧ នៃអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ)

៤.យោធិនគ្រប់រូប ក្នុងពេលបម្រើការងារ ត្រូវស្លៀកពាក់ឯកសណ្ឋានដែលមានសក្តិ ស្លាកសញ្ញា បរិក្ខាររួមផ្សំផ្សេងៗ តាមការចាំបាច់ និងតាមការកំណត់របស់មេបញ្ជាការ ឬការកំណត់ក្នុងពិធីនីមួយៗ ការធ្វើដំណើរក្រៅបរិវេណអគារ ដាច់ខាតត្រូវពាក់មួក និងការត្រួតពិនិត្យការស្លៀកពាក់ គឺការទទួលខុសត្រូវជាអចិន្ត្រៃយ៍នៅគ្រប់លំដាប់ថ្នាក់នៃឋានានុក្រម។ (ដូចមានចែងក្នុងជំពូកទី៥មាត្រា២៧ នៃអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់.ខ.ភ និងប្រកាសលេខ៤៩/២០១៧ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ស្តីពីការប្រើប្រាស់ឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ.ខ.ភ.ម)

-យោធិនគ្រប់រូបត្រូវគោរពបទបញ្ជា ពេលអនុវត្តការងារ ត្រូវធ្វើតាមឋានានុក្រម និងយោធិនអាជីពត្រូវហាមដាច់ខាតមិនឱ្យយកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិពលរដ្ឋ។(ដូចមានចែងក្នុងជំពូកទី៤ មាត្រា២៥នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃ.ខ.ភ.ម និងជំពូកទី២មាត្រា៣,៤ នៃអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ)

៥.ការកាត់សក់ ការទុកក្រចកដៃត្រូវធ្វើឱ្យបានត្រឹមត្រូវតាមក្បួនអនាម័យ សមនឹងឯកសណ្ឋានព្រមទាំងសម្ភារៈ បរិក្ខារប្រើប្រាស់រួមផ្សំផ្សេងៗទៀត។ ដូច្នេះចាំបាច់តម្រូវឱ្យមានការកម្រិតប្រវែងសក់ និងមិនអនុញ្ញាតឱ្យទុកពុកមាត់ជាដាច់ខាត(ដូចមានចែងក្នុងជំពូកទី៥ មាត្រា២៩ នៃអនុក្រឹត្យស្តីពីបទ-វិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ)

៦.ការគំនាប់ ជាកាតព្វកិច្ចដែលយោធិនម្នាក់ៗត្រូវធ្វើគារវកិច្ច និងជាការបង្ហាញបញ្ជាក់នូវការ

គួរសមរបស់យោធិនដែលស្លៀកពាក់ឯកសណ្ឋាន។ យោធិនគ្រប់រូបត្រូវគំនាប់ដល់យោធិនដែលមានឋានន្តរសក្តិ ឬមុខតំណែងខ្ពស់ជាង ក្នុងករណីឋានន្តរសក្តិនិងមុខតំណែងស្មើគ្នា ត្រូវគិតពីអតីតភាពនៃការដំឡើងឋានន្តរសក្តិ ឬមុខតំណែងមុនៈ

-ក្នុងកន្លែងធ្វើការ សាលប្រជុំ ថ្នាក់រៀន ពិធីនានារបស់យោធា និងការប្រមូលផ្តុំ ឬការសម្រាកដែលមានគ្នាចាប់ពីពីរនាក់ឡើងទៅ បើមានថ្នាក់ឧត្តមសេនីយ៍ណាម្នាក់ចូលទៅយោធិនដែលក្រឡេកឃើញមុនគេ ឬមេបញ្ជាការ ឬអ្នកប្រចាំការ ត្រូវស្រែកបញ្ជាថា "តាមកន្លែងរៀងខ្លួនគោរព" បើថ្នាក់វរសេនីយ៍ត្រូវស្រែក "តាមកន្លែងគោរព" បើថ្នាក់អនុសេនីយ៍ត្រូវស្រែក "គោរព" និងបើនាយទាហានរងចុះក្រោមត្រូវស្រែក "ប្រុង" (ដូចមានចែងក្នុងជំពូកទី៥ មាត្រា៣០និង៣១ នៃអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ)

៧.ជាទូទៅក្នុងកន្លែងស្នាក់នៅរបស់យោធា មានជាអាទិ៍ ក្នុងបរិវេណ អគារ ឬយន្តហោះយោធា ឬនាវាយោធាត្រូវបានហាមឃាត់ៈ

-ការលេងល្បែងស៊ីសងគ្រប់ប្រភេទ

-ការនាំចូលដោយគ្មានការអនុញ្ញាត នូវគ្រឿងពុល វត្ថុងាយឆេះ ឬគ្រឿងផ្ទុះនិងគ្រឿងស្រវឹង

-ការនាំចូលទស្សនាវដ្តី កាសែត សៀវភៅ រូបថត ឬការផ្សព្វផ្សាយដែលនាំឱ្យប៉ះពាល់ដល់សីលធម៌ និងវិន័យយោធា។

យោធិនគ្រប់រូបត្រូវរក្សាការសម្ងាត់យោធា និងមិនត្រូវធ្វើឱ្យឯកសារយោធា បាត់បង់ ធ្លាក់ដល់ដៃអ្នកដទៃ ឬធ្វើឱ្យអ្នកដទៃបានដឹងឡើយ។

ការប្រើប្រាស់ ប្រដាប់ថតរូប ថតភាពយន្ត ថតសំឡេង ការផ្សាយព័ត៌មានតាមប្រព័ន្ធផ្សេងៗ ការផ្សព្វផ្សាយ ការលក់រូបថត ការថតសំឡេង ការសម្ភាសន៍ ឬការផ្តល់ព័ត៌មានទៅក្រៅ អំពីក្នុងបរិវេណយោធា អគារយោធា លើនាវាយោធា ក្នុងពេលធ្វើការ ឬប្រតិបត្តិការ ឬបេសកកម្មយោធា ចាំបាច់ត្រូវមានការអនុញ្ញាត ពីមេបញ្ជាការដែលទទួលខុសត្រូវខ្ពស់បំផុតនៅទីនោះ ឬពេលនោះ(ដូចមានចែងក្នុងជំពូកទី៥ មាត្រា៣៤និង៣៥ នៃអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ)

៨.ការគំនាប់ផ្អែកតាមបទវិន័យទូទៅរបស់កងយោធពលខេមរភូមិន្ទ យោធិនគ្រប់រូបត្រូវអនុវត្តមួយថ្ងៃពីរដង (ព្រឹកម្តង-ល្ងាចម្តង)ចំពោះអ្នកដែលមានឋានន្តរសក្តិ ឬមុខតំណែងខ្ពស់ជាង តែក្នុងករណីយោធិនណាម្នាក់ដែលត្រូវចូលជួបនាយ ឬមេបញ្ជាការរបស់ខ្លួន ត្រូវគំនាប់រាល់ពេលចូលជួបជានិច្ច។

-យោធិនគ្រប់រូប ត្រូវធ្វើកាយវិការគំនាប់ឱ្យបានត្រឹមត្រូវ តាមឯកសារលំហាត់របៀបរបស់កង-យោធពលខេមរភូមិន្ទ

-មានមួកត្រូវលើកដៃគំនាប់ និងគ្មានមួកគោរពដោយកាយវិការប្រុង (មិនត្រូវលើកដៃគំនាប់ទេ)

-ក្នុងពេលថ្នាក់លើបំពាក់ឋានន្តរសក្តិនិងគ្រឿងឥស្សរិយយសគ្រប់ប្រភេទ យោធិនត្រូវស្លៀកពាក់ឯកសណ្ឋាន ដោយមានមួក ក្រោយពីគំនាប់ថ្នាក់លើរួច ត្រូវឈរក្នុងកាយវិការប្រុង មិនលើកដៃគំនាប់ទៀតទេ។ ចំពោះកាយវិការគោរពកិច្ចនិងលំដាប់លំដោយក្នុងពិធីបំពាក់ឋានន្តរសក្តិនិងគ្រឿងឥស្សរិយយសនេះត្រូវអនុវត្តតាមឯកសារលំហាត់របៀបបានកំណត់

-ក្នុងការគោរពទង់ជាតិ គណៈប្រតិភូបំពេញបេសកកម្មនៅក្រៅនិងក្នុងប្រទេស និងនាយទាហានអធិបតី ភ្ញៀវកិត្តិយស អមដំណើរក្នុងពិធីនានាដែលស្ថិតនៅលើវេទិកា ខាងក្រោយអធិបតីក្នុងពេលគោរពទង់ជាតិ ក្នុងឯកសណ្ឋានមានមួកត្រូវលើកដៃគំនាប់ទាំងអស់គ្នា

-ក្នុងការគោរពវិញ្ញាណក្ខន្ធមានមួកត្រូវធ្វើកាយវិការឱនក្បាលចុះបន្តិច(ដោយមិនដោះមួកនិងមិនលើកដៃគំនាប់ទេ)

-នាយ ឬមេបញ្ជាការគ្រប់រូប ពេលយោធិនណាម្នាក់គោរពឬគំនាប់ ត្រូវសម្តែងកាយវិការទទួលយកនូវការគោរពនោះ ដោយកាយវិការគោរពតបវិញ ឬដោយលើកដៃ ឬងក់ក្បាល ឬនិយាយក្នុងអត្ថន័យទទួលយកការគោរពនោះ

-ការធ្វើគារវកិច្ចចំពោះព្រះមហាក្សត្រ ក្នុងឯកសណ្ឋានមានមួកត្រូវលើកដៃគំនាប់ គ្មានមួកដោយកាយវិការប្រុង ក្នុងករណីព្រះមហាក្សត្រចាប់ដៃ ត្រូវលំឱនកាយឱ្យទាបជាង

-ការធ្វើគារវកិច្ចចំពោះព្រះសង្ឃ ក្នុងឯកសណ្ឋានមានមួកត្រូវដោះមួករួចលើកដៃសំពះ និងការជួបមនុស្សចាស់ទុំជាការគួរសមត្រូវដោះមួកឬលើកដៃសំពះដូចគ្នា

៩.ផ្អែកតាមមាត្រា២៧នៃអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ ពេលដើរចេញក្រៅអគារ យោធិនគ្រប់រូបត្រូវពាក់មួកជាការចាំបាច់។

-ការចាត់តាំងពិធីនានារបស់កងយោធពលខេមរភូមិន្ទក្នុងអគារ យោធិនគ្រប់រូបចូលរួមមិនបាច់ពាក់មួកឡើយ លើកលែងតែគណៈចាត់តាំងកម្មវិធី និងពេលបំពាក់សក្តិ ឬគ្រឿងឥស្សរិយយស និងការផ្តល់រង្វាន់ បណ្ណសរសើរ លិខិតសរសើរ និងសញ្ញាបត្រផ្សេងៗ

-ការចាត់តាំងពិធីនៅទីលានត្រូវពាក់មួកជានិច្ច ទាំងគណៈអធិបតីនិងយោធិនចូលរួម ទោះបីពិធីនោះបានធ្វើនៅលើវេទិកាគណៈអធិបតីក៏ដោយ និងយោធិនដែលឈរលើទីលាន ក៏ត្រូវពាក់មួកគ្រប់គ្នា

-ការធ្វើគារវកិច្ចក្នុងការិយាល័យ ក្នុងបរិវេណបន្ទាយ ឬក្នុងអគារ តាមទីសាធារណៈ ឬតាមភោជនីយដ្ឋាន និងពេលធ្វើដំណើរតាមយានយន្ត ត្រូវអនុវត្តតាមកាយវិការដូចមានចែងក្នុងឯកសារលំហាត់របៀបរបស់កងយោធពលខេមរភូមិន្ទ

-យោធិនគ្រប់រូបត្រូវធ្វើការគំនាប់ដល់មន្ត្រីរាជការស៊ីវិលដែលមានមុខតំណែងខ្ពស់ជាង ការធ្វើគារវកិច្ចចំពោះជនស៊ីវិលដូចជាគ្រួសារ(ភរិយា)របស់ថ្នាក់លើ ដោយដោះមួកឬលើកដៃសំពះ និងនិយាយថា"ជម្រាបសួរ"ជាការគួរសមតាមសុជីវធម៌របស់ខ្មែរ។(ដែលមានចែងក្នុងទំព័រ៦៣ ចំណុចថ-និងទ-នៃឯកសារលំហាត់របៀប តាមសេចក្តីសម្រេចលេខ៣៨ សសរ.ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០២"របស់អគ្គបញ្ជាការដ្ឋាន")

១០.ការរៀបចំពិធី បើកឬបិទវគ្គ មីទ្ទីងនិងពិធីផ្សេងៗដែលមានការប្រមូលផ្តុំទ័ព និងគណៈអធិបតីចូលរួមច្រើនត្រូវចាត់តាំងឱ្យមានការឯកភាពគ្នានិងមានសណ្តាប់ធ្នាប់ស្របតាមបទវិន័យទូទៅនិងឯកសារលំហាត់របៀបរបស់កងយោធពលខេមរភូមិន្ទ។

១១.ការរៀបចំកងកិត្តិយស កងសាប និងត្រែទ័ពសម្រាប់បដិសណ្ឋារកិច្ចភ្ញៀវជាតិនិងអន្តរជាតិ តាមពិធីការរដ្ឋនិងយោធា ព្រមទាំងពិធីនានា ដែលផ្តល់កិត្តិយសឱ្យមានការរៀបចំអាវុធគ្រាស។ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមប្រកាសលេខ៤៩/២០១៧ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ស្តីពីការប្រើប្រាស់ឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យកងយោធពលខេមរភូមិន្ទ។

១២.ការធ្វើគារវកិច្ចនិងកាយវិការរបស់យោធិនម្នាក់ៗដែលបំពេញបេសកកម្មក្រៅប្រទេសដូចជាគណៈប្រតិភូយោធា មន្ត្រីការទូតយោធា បំពេញការសិក្សា។ល។ ត្រូវអនុវត្តតាមឯកសារលំហាត់របៀបរបស់កងយោធពលខេមរភូមិន្ទ និងយោធិនដែលបានបញ្ចប់ការសិក្សាពីក្រៅប្រទេសវិញ មិនអនុ-

ញ្ញាតឱ្យយកកាយវិការគារវកិច្ច ឬសណ្តាប់ធ្នាប់យោធារបស់ប្រទេសជាមិត្តមកអនុវត្តក្នុងកងយោធពលខេមរភូមិន្ទឡើយ។

១៣.យោធិនគ្រប់រូប ត្រូវស្លៀកពាក់ឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទ គ្រប់ប្រភេទ ដែលមានចែងក្នុងអនុក្រឹត្យ លេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋានស្លាកសញ្ញា និងទង់ជ័យនៃ.ខ.ភ.ម និងមិនអនុញ្ញាតឱ្យស្លៀកពាក់ឯកសណ្ឋានផ្សេងៗក្រៅពីការកំណត់ក្នុងអនុក្រឹត្យនេះឡើយ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

១៤.អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយកមេបញ្ជាការ នាយក ប្រធានស្ថាប័នគ្រប់កងឯកភាព ចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ត្រូវយកចិត្តទុកដាក់ ចាត់ចែងរៀនសូត្រ ផ្សព្វផ្សាយនិងរំឭកជាប្រចាំ ដល់យោធិនគ្រប់រូប ទោះបីធ្លាប់រៀនសូត្ររួចហើយក៏ដោយ អំពីច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃ.ខ.ភ.ម អនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់.ខ.ភ.ម. អនុក្រឹត្យស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃ.ខ.ភ.ម ប្រកាសស្តីពីការប្រើប្រាស់ឯកសណ្ឋាន ស្លាកសញ្ញានិងទង់ជ័យ កងកិត្តិយយ ត្រៃទ័ពនៃ.ខ.ភ.ម ឯកសារលំហាត់របៀប និងបទដ្ឋាននានាពាក់ព័ន្ធនឹងកងយោធពលខេមរភូមិន្ទដើម្បីធ្វើឱ្យយោធិនអនុវត្តមានការឯកភាពគ្រប់សណ្តាប់ធ្នាប់និងរបៀបរបបចាត់តាំងពិធីនានាក្នុងកងយោធពលខេមរភូមិន្ទ ព្រមទាំងឈានទៅពង្រឹងវិន័យឱ្យបានម៉ឺងម៉ាត់បំផុត។

១៥.បានទទួលសេចក្តីណែនាំនេះ គ្រប់ស្ថាប័នកងឯកភាព ចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ត្រូវទទួលបន្ទុកម្ចាស់ការអនុវត្ត តាមខ្លឹមសារសេចក្តីណែនាំនេះ ក្នុងកងឯកភាពរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩កើត ខែទុតិយាសាឍ ឆ្នាំជូតទោស័កព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ-បាញ់**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ឯកឧត្តមលោកជំទាវរដ្ឋលេខាធិការ
និងអនុរដ្ឋលេខាធិការ .កពជ
-ខុទ្ទកាល័យសម្តេចពិជ័យសេនាទៀ បាញ់
-ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន.ខ.ភ.ម
-ឯកសារ កាលប្បវត្តិ